អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
ដើម្បីចូលរួមចំណែកការពារ និង ការអភិវឌ្ឍន៍មាតុភូមិកម្ពុជា
To Pay Tax Is The Obligation For All Cambodian People And
To Contribute To The Defense And Development Of Our Nation!




# ប្រកាសស្តីពី
# ការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធ
# របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល


បទបង្ហាញដោយ
**លោក ប៉ុ ពិសិដ្ឋ**
អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម

# មាតិកា

**១. ទិដ្ឋភាពទូទៅ**

១.១. គោលបំណង និងគោលដៅ

១.២. និយមន័យ

**២. ការលើកលែងពន្ធលើប្រាក់ចំណូល**

២.១. ប្រាក់ចំណូលលើកលែងពន្ធ

២.២. ការទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល

**៣. កាតព្វកិច្ចសារពើពន្ធ**

២.១. ចុះបញ្ជីពន្ធដារ

២.២. ការប្រកាសបង់ពន្ធ

**៤. សកម្មភាពអាជីវកម្មដោយឡែក**

# ១. និដ្ឋភាពទូទៅ

# ១.១. គោលបំណង និងគោលដៅ

- គោលបំណងពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- គោលដៅផ្តល់ការណែនាំបន្ថែមអំពីកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តធានាការអនុវត្តប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

# ១.២. និយមន័យ

- **សមាគម** សំដៅដល់អង្គការសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល ដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។ សមាគមរួមបញ្ចូលផងដែរនូវ សភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម។ សមាគមដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាហៅថា **សមាគមក្នុងស្រុក** រីឯសមាគមបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាហៅថា **សមាគមបរទេស**។

# ១.២. និយមន័យ

- **អង្គការមិនមែនរដ្ឋាភិបាល** សំដៅដល់អង្គការមិនមែនសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល រួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គលក្រៅពីស្ថាប័នរដ្ឋាភិបាល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។ អង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាហៅថា **អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** រីឯអង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាហៅថា **អង្គការមិនមែនរដ្ឋាភិបាលបរទេស។**

# ១.២. និយមន័យ

- **សកម្មភាពគោលដៅសុទ្ធសាធ÷**

១.អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សកម្មភាព ដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។

២.សមាគម សំដៅដល់សកម្មភាពរបស់សមាគម ដែលប្រាក់ចំណូលមិនត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល។

- **សកម្មភាពមិនស្ថិតក្នុងគោលដៅសុទ្ធសាធ** សំដៅដល់សកម្មភាពអាជីវកម្មដោយឡែករបស់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិ ក្រៅពីសកម្មភាពគោលដៅសុទ្ធសាធ។

# ២. ការលើកលែង ពន្ធលើប្រាក់ចំណូល

# ២.១. ប្រាក់ចំណូលលើកលែងពន្ធ

- ប្រាក់ចំណូល ដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់សកម្មភាពគោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។ ចំណូលទាំងនោះរួមមាន មូលនិធិឬអំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល ធនធាននិងទ្រព្យសម្បត្តិរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល ភាគទានឬវិភាគទានឬបរិវិសទានរបស់សមាជិក និងចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត វៀរលែងតែ ចំណូលពីសកម្មភាពអាជីវកម្មដោយឡែក។
- ប្រាក់ចំណូលមិនជាប់ពន្ធ ដូចមានក្នុងមាត្រា៩ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ

# ២.២. ការទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល

- ដាក់ពាក្យស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលមកអគ្គនាយកដ្ឋានពន្ធដារ
- ឯកសារភ្ជាប់
  - លក្ខន្តិកៈ និងលិខិតអនុញ្ញាតចុះបញ្ជីនៅក្រសួងមហាផ្ទៃ (សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)
  - អនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស)
  - ត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដាររាល់ការផ្លាស់ប្តូរលក្ខខណ្ឌនានា ក្នុងអំឡុងពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយមានការផ្លាស់ប្តូរ




# ៣. ភាតព្វកិច្ចសារពើពន្ធ របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

# ៣.១. ការចុះបញ្ជីពន្ធដារ

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវមានកាតព្វកិច្ចចុះបញ្ជីសារពើពន្ធ ក្នុងអំឡុងពេល **១៥** ថ្ងៃ÷

១. ក្រោយពីចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច

២. ក្រោយមានការផ្លាស់ប្តូរកម្មវត្ថុអាជីវកម្មឬសកម្មភាពអាជីវកម្ម អាសយដ្ឋាន នាមករណ៍ សមាសភាពអ្នកគ្រប់គ្រង ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង (លេខទូរស័ព្ទ ឬសារអេឡិចត្រូនិក) ...។ល។

**សកម្មភាពសេដ្ឋកិច្ច** សំដៅដល់សកម្មភាព របស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

# ៣.២. ការប្រកាសបង់ពន្ធ

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពគោលដៅសុទ្ធសាធ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ÷

  ១. បង់ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ប្រចាំខែ

  ២. លិខិតប្រកាសពន្ធប្រចាំឆ្នាំ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធរួមមានព័ត៌មានគណនីធនាគារ របាយការណ៍ហិរញ្ញវត្ថុ កិច្ចព្រមព្រៀងហិរញ្ញប្បទាន ផែនការគម្រោងសកម្មភាព របាយការណ៍សកម្មភាពអនុវត្តគម្រោង ។ល។

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពមិនស្ថិតក្នុងគោលដៅសុទ្ធសាធ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ រួមមាន ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម និងពន្ធអាករដទៃទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

# ៤. សកម្មភាពអាជីវកម្មដោយឡែក

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក មិនស្ថិតក្នុងគោលដៅសុទ្ធសាធ ត្រូវ៖

១. ចុះបញ្ជីពន្ធដារដាច់ដោយឡែកមួយទៀតនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃ ក្រោយពីមានសកម្មភាពអាជីវកម្ម នឹងត្រូវចាត់ទុកជាសហគ្រាសឯកបុគ្គល

២. ចុះបញ្ជីពន្ធដារតាមកម្រិតផលរបរ និងប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ស្របតាមប្រកាសលេខ ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្ដីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣. បង់ពន្ធប៉ាតង់ ស្របតាមប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០២១ ស្ដីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ៤. សកម្មភាពអាជីវកម្មដោយខ្សែក

សំណុំឯកសារភ្ជាប់ទាំងអស់ដែលជាច្បាប់ថតចម្លងដែលតម្រូវឱ្យភ្ជាប់ សម្រាប់ការចុះបញ្ជីពន្ធដារត្រូវមានការបញ្ជាក់ "ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" ពីមន្ត្រីពន្ធដារមានសមត្ថកិច្ច ឬពីក្រសួង ស្ថាប័នពាក់ព័ន្ធ"

- **សម្រាប់អ្នកជាប់ពន្ធតូច**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ S01) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើស ៣ ខែ ទំហំ ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ២ សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាងសមាគម ឬអង្គការនានា |
| ៤ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| **ឯកសារត្រូវភ្ជាប់បន្ថែម បើមាន៖** | |
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |

# ៤. សកម្មភាពអាជីវកម្មដោយខ្សែក

## ▪ សម្រាប់អ្នកជាប់ពន្ធមធ្យម-ធំ

| ឯកសារតម្រូវ | |
| --- | --- |
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ ១០១) |
| ២ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង |
| ៣ | លក្ខន្តិកៈរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយខ្សែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារឬសៀវភៅធនាគារ ដែលចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៦ | រូបថតបច្ចុប្បន្នមិនលើស ៣ ខែ ទំហំ ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ២ សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាងសមាគម ឬអង្គការនានា |
| ៧ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| ៨ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |

# ៤. សកម្មភាពអាជីវកម្មដោយខ្លែក

## ទម្រង់ S01 (អ្នកជាប់ពន្ធតូច)



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ / FORM S 01

សម្រាប់បិទបាកូដ / Stick bar code here!

ពាក្យស្នើសុំចុះបញ្ជីពន្ធដារ
(សម្រាប់អ្នកជាប់ពន្ធតូច)
APPLICATION FORM FOR TAX REGISTRATION
(FOR SMALL BUSINESS)

I. ព័ត៌មានអាជីវកម្មដ្ឋាន / BUSINESS INFORMATION

ប្រសិនបើអាជីវកម្មរបស់លោកអ្នកធ្លាប់បានចុះបញ្ជីពន្ធដារហើយ សូមបំពេញលេខសម្គាល់អាជីវកម្ម
If your business already registered, please fill in Business identification number (BIN)

ឈ្មោះអាជីវកម្មដ្ឋាន
Name of business

ឈ្មោះអាជីវកម្មដ្ឋានជាអក្សរឡាតាំង
Name of business in Latin

ឆ្នាំជាប់ពន្ធរបស់សហគ្រាស
Tax year for enterprise

ចាប់ពី
Start date
D D M M

ដល់
End date
D D M M

1. អាសយដ្ឋានរបស់អាជីវកម្ម / BUSINESS ADDRESS

សម្រាប់អាជីវកម្មក្នុងផ្សារ / FOR BUSINESS IN THE MARKET

ឈ្មោះផ្សារ
Name of market

តូបលេខ
Stall №

ច្រកលេខ
Gate №

## ទម្រង់ 101 (អ្នកជាប់ពន្ធមធ្យម-ធំ)



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ ១០១ / FORM 101

Reset Form

ពាក្យស្នើសុំចុះបញ្ជីពន្ធដារ
និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
APPLICATION FORM FOR TAX REGISTRATION / TAXPAYER INFORMATION UPDATE

I- កាតព្វកិច្ចចុះបញ្ជី/បច្ចុប្បន្នភាពព័ត៌មាន / OBLIGATION OF REGISTRATION/UPDATE INFORMATION

ស្នើសុំ៖
Apply for:

☐ ចុះបញ្ជីពន្ធដារ
Tax registration
▶ សូមបំពេញព័ត៌មាន និងភ្ជាប់ឯកសារទៅតាមផ្នែកនៃទម្រង់ទ្រាយគតិយុត្តនីមួយៗ
Please fill out the information and attach the documents required by following each part of the legal form

☐ បច្ចុប្បន្នភាពព័ត៌មាន
Information Update
▶ សូមបំពេញព័ត៌មានតាមផ្នែកដែលមានការផ្លាស់ប្ដូរ និងភ្ជាប់ឯកសារតាមឧបសម្ព័ន្ធស្ដីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន
Please fill out the information that have been updated in the relevant sections and attach the documents required by following the "Annex on Requirement Documents for Information Update"

សម្គាល់៖
Note:

| | ទម្រង់ទ្រាយគតិយុត្ត / LEGAL FORM | ផ្នែក/PART |
|---|---|---|
| ☐ | 1. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល /State Institution, Diplomatic Mission, Foreign Consulate, International Organization, Technical Cooperation Agency of Other Governments, Political Party, Association and Non-government Organization | 101-P1 |
| ☐ | 2. ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត) /Limited Company (Private / Public Limited Company) | 101-P2 |

# ៤. សកម្មភាពអាជីវកម្មដោយខ្មែរ

➢ *ប្រកាសលេខ ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្ដីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

| វិស័យចម្បងៗ | អ្នកជាប់ពន្ធតូច | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធធំ |
|---|---|---|---|
| | កម្រិតផលរបរប្រចាំឆ្នាំ | | |
| វិស័យកសិកម្ម | ចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល | លើសពី ៤ ០០០ លានរៀល |
| វិស័យសេវាកម្ម | ចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល | លើសពី ៦ ០០០ លានរៀល |
| វិស័យពាណិជ្ជកម្ម | ចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល | លើសពី ៦ ០០០ លានរៀល |
| វិស័យឧស្សាហកម្ម | ចាប់ពី ២៥០ លានរៀល ដល់ ១ ៦០០ លានរៀល | លើសពី ១ ៦០០ លានរៀល ដល់ ៨ ០០០ លានរៀល | លើសពី ៨ ០០០ លានរៀល |
| ផ្សេងៗ | -ផលរបរក្នុងរយៈពេល ៣ខែ ជាប់គ្នាដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០ លានរៀល ឡើងទៅ<br>-រំពឹងថាមានផលរបរក្នុងរយៈពេល ៣ខែ ជាប់គ្នាខាងមុខ ចាប់ពី ៦០ លានរៀលឡើងទៅ<br>-ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា រួមទាំងភាស៊ី | -សហគ្រាសចុះបញ្ជីជានីតិបុគ្គល<br>-ការិយាល័យតំណាង<br>-ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬគម្រោងស្ថិតក្រោមស្ថាប័នទាំងនេះ<br>-សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល<br>-បេសកកម្មទូត និងកុងស៊ុលបរទេស<br>-អង្គការអន្តរជាតិ<br>-ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងស្ថិតក្រោមស្ថាប័នទាំងនេះ | -បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ<br>-សាខាក្រុមហ៊ុនបរទេស<br>-QIP |

# ៤. សកម្មភាពអាជីវកម្មដោយខ្សែក

- *ប្រកាសលេខ ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*** ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែងរបស់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលបានប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសដូចខាងក្រោម÷

| វិស័យចម្បងៗ | អ្នកជាប់ពន្ធតូច | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធធំ |
|---|---|---|---|
| | តម្លៃទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ | | |
| វិស័យកសិកម្ម | ចាប់ពី ២០០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល | លើសពី ២ ០០០ លានរៀល |
| វិស័យសេវាកម្ម | ចាប់ពី ២០០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល | លើសពី ២ ០០០ លានរៀល |
| វិស័យពាណិជ្ជកម្ម | ចាប់ពី ២០០ លានរៀល ដល់ ១ ០០០ លានរៀល | លើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល | លើសពី ២ ០០០ លានរៀល |
| វិស័យឧស្សាហកម្ម | ចាប់ពី ២០០ លានរៀល ដល់ ២ ០០០ លានរៀល | លើសពី ២ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល | លើសពី ៤ ០០០ លានរៀល |

# ៤. សកម្មភាពអាជីវកម្មដោយឡែក

- *សេចក្តីណែនាំលេខ ៣០៣៣ អពដ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល*

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក ត្រូវ÷

១.ញែកដាច់ពីគ្នារវាង ដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗ ដែលសម្រាប់បម្រើឱ្យសមាគម ឬអង្គការមិនមែនរដ្ឋភិបាល និងដែលសម្រាប់បម្រើឱ្យសកម្មភាពអាជីវកម្មដោយឡែក។

២.អ្នកជាប់ពន្ធតូច÷ អនុវត្តវិធាននិងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញស្របតាមប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាននិងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច

៣.អ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ÷ អនុវត្តវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល


បើកប្រាក់ខែជូនមន្ត្រីរាជការ
To Pay Salary For Civil Servants
សាងសង់មន្ទីរពេទ្យ
To Build Hospitals
To Pay Salary For Soldiers And Forces
សាងសង់ផ្លូវ
To Build Roads
TAXES
សាងសង់ស្ពាន
To Build Bridges
ការពារព្រំដែន
To Defend Borders & Heritages
សាងសង់សាលារៀន
To Build Schools

# សូមអរគុណ!